ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

លេខ ៖ ៩១ ស.ជ.ណ.

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកដំណើរការឡើងវិញនូវការចូលទស្សនាសារមន្ទីរ រោងភាពយន្ត និងរោងសម្តែងសិល្បៈនៅក្នុងរាជធានីភ្នំពេញ

យោងសេចក្តីសម្រេចលេខ៣២៤/២១សសរ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ របស់សាលារាជធានីភ្នំពេញ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានកិត្តិយសសូមជម្រាបជូនដំណឹងចំពោះលោកប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ម្ចាស់រោងសម្តែងសិល្បៈ ម្ចាស់រោងភាពយន្ត សាធារណជន សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ អន្តរជាតិទាំងអស់មេត្តាជ្រាបថា ផ្អែកលើការវិវត្តន៍កាន់តែប្រសើរឡើងនៃស្ថានភាពជំងឺកូវីដ-១៩ ក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចបើកប្រទេសឡើងវិញជាបណ្តើរៗ និងតាមដំណាក់កាលជាមួយភាពប្រយ័ត្នប្រយែង និងការទទួលខុសត្រូវខ្ពស់តាមគន្លងប្រក្រតីភាពថ្មី។

ក្នុងន័យនេះ ដើម្បីចូលរួមចំណែកបើកដំណើរការឡើងវិញនូវសកម្មភាពសេដ្ឋកិច្ច និងសង្គម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រេចអនុញ្ញាតឲ្យបើកដំណើរការឡើងវិញនូវការចូលទស្សនាសារមន្ទីរ រោងភាពយន្ត និងរោងសម្តែងសិល្បៈ នៅក្នុងរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ នេះតទៅ ដោយត្រូវអនុវត្តឲ្យបានម៉ត់ចត់បំផុតនូវវិធានការគោលការណ៍ស្តង់ដាប្រតិបត្តិ (SOP) ដែលរៀបចំឡើងរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសុខាភិបាល ព្រមទាំងសេចក្តីណែនាំនានារបស់ក្រសួងសុខាភិបាល។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ម្ចាស់រោងភាពយន្ត ម្ចាស់រោងសម្តែងសិល្បៈ សាធារណជន សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ទីភ្នាក់ងារទេសចរណ៍ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ អន្តរជាតិទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងសូមអនុវត្តតាមសេចក្តីជូនដំណឹងនេះដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១

ទូរសព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# គោលការណ៍ស្តង់ដាប្រតិបត្តិ (SOP) សម្រាប់រោងភាពយន្ត និងរោងសម្តែងសិល្បៈ

ផ្អែកលើមូលដ្ឋាននៃការគ្រប់ដណ្តប់ការចាក់វ៉ាក់សាំងកូវីដ-១៩ ដើម្បីបង្កើតឲ្យមានប្រព័ន្ធភាពស៊ាំក្នុងសហគមន៍ ដែលមកដល់ពេលនេះសម្រេចបានរហូតជាង៨០% លើចំនួនប្រជាជនសរុប ១៦លាននាក់ និងយោងលើការវិវត្តន៍កាន់តែប្រសើរឡើងនៃស្ថានភាពជំងឺកូវីដ-១៩ ក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានសម្រេចបើកប្រទេសឡើងវិញជាបណ្តើរៗ និងតាមដំណាក់កាលជាមួយភាពប្រយ័ត្នប្រយែង និងការទទួលខុសត្រូវខ្ពស់តាមគន្លងប្រក្រតីភាពថ្មី។

ដើម្បីចូលរួមចំណែកបើកដំណើរការឡើងវិញនូវសកម្មភាពសេដ្ឋកិច្ច និងសង្គម ដោយអនុវត្តតាមវិធានការ ៣ការពារ ៣កុំ ក្នុងការទប់ស្កាត់ការចម្លងរីករាលដាលជំងឺកូវីដ-១៩ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសហការជាមួយក្រសួងសុខាភិបាល បានរៀបចំឡើងនូវគោលការណ៍ស្តង់ដាប្រតិបត្តិ (SOP) សម្រាប់រោងភាពយន្ត និងរោងសម្តែងសិល្បៈអនុវត្ត ក្នុងពេលបើកដំណើរការឡើងវិញ តាមខ្លឹមសារដូចខាងក្រោម៖

## ១- វិធានការការពារការឆ្លងវីរុសកូវីដ-១៩

### ១.១- ការបង្ហាញបណ្ណចាក់វ៉ាក់សាំង

- ត្រូវពិនិត្យនិងស្នើឲ្យទស្សនិកជនគ្រប់រូប ដែលមករោងភាពយន្ត ឬ រោងសម្តែងសិល្បៈត្រូវបង្ហាញបណ្ណចាក់វ៉ាក់សាំងការពារវីរុសកូវីដ-១៩ ឬ ស្កេន QR Code របស់ក្រសួងសុខាភិបាល។ ករណីនេះ ត្រូវបានលើកលែងចំពោះទស្សនិកជនដែលមានអាយុក្រោម ៦ឆ្នាំ។






## ១.២- ការពាក់ម៉ាស់ និងវាស់សីតុណ្ហភាព

- ត្រូវវាស់ស្ទង់សីតុណ្ហភាពចំពោះទស្សនិកជនគ្រប់រូប ដែលចេញចូលក្នុងបរិវេណរោងភាពយន្ត ឬរោងសម្ដែងសិល្បៈ និងតម្រូវឱ្យទស្សនិកជនគ្រប់រូប ពាក់ម៉ាស់ការពារជានិច្ច។
- បើពិនិត្យឃើញករណីសង្ស័យណាមួយ ត្រូវរក្សាទុកទស្សនិកជនដែលជាអ្នកសង្ស័យនោះ ក្នុងបន្ទប់រង់ចាំដាច់ដោយឡែក និងត្រូវរាយការណ៍ជាបន្ទាន់មកមន្ត្រីជំនាញសុខាភិបាល។
- ត្រូវយកចិត្តទុកដាក់ជាពិសេស ចំពោះស្ត្រីមានផ្ទៃពោះ ជនចាស់ជរា និងកុមារតូចៗដែលជាជនងាយរងគ្រោះ ដោយកាត់បន្ថយឱ្យបានជាអតិប្បរិមានូវការជួបជុំគ្នា ដែលអាចជាកត្តាហានិភ័យខ្ពស់ក្នុងការចម្លងវីរុសកូវីដ១៩។






## ១.៣- ការទិញសំបុត្រ

- ត្រូវរិះរកវិធានការលើកទឹកចិត្តឲ្យទស្សនិកជនទិញសំបុត្រតាមអនឡាញ(Online) ឬតាមអែប (App) របស់រោងភាពយន្ត ឬរោងសម្ដែងសិល្បៈ ដើម្បីកាត់បន្ថយការលក់សំបុត្រដោយផ្ទាល់នៅហ្នឹងកន្លែង តាមដែលអាចធ្វើបាន។
- ត្រូវរៀបចំដាក់សញ្ញាសម្គាល់ដើម្បីឱ្យទស្សនិកជនឈររង់ចាំ ដោយរក្សាគំលាតឲ្យបានយ៉ាងតិច ១.៥០ម ក្នុងករណីទស្សនិកជនទិញសំបុត្រផ្ទាល់នៅបញ្ជរលក់សំបុត្រ។






## ១.៤- ការចល័តក្នុងបរិវេណរោងភាពយន្ត ឬរោងសម្តែងសិល្បៈ

- ការចល័តក្នុងរោងភាពយន្ត ឬរោងសម្តែងសិល្បៈ ត្រូវគោរពតាមស្លាកសញ្ញាចេញចូលនៃលំហូរមនុស្សដែលបានដាក់បង្ហាញ។ ដើម្បីកាត់បន្ថយការចល័តចុះឡើងនៅក្នុងរោង ទស្សនិកជនដែលមានបំណងទិញអាហារសម្រន់ ឬចូលបន្ទប់ទឹក ត្រូវធ្វើឲ្យបានមុនពេលចូលក្នុងរោងបញ្ចាំង ឬរោងសម្តែង។
- ត្រូវកាត់បន្ថយចំនួនទស្សនិកជន ដែលមកមុនម៉ោងយូរពេក ដើម្បីចៀសវាងការប្រមូលផ្តុំ និងការចល័តក្នុងបរិវេណរោងភាពយន្ត ឬរោងសម្តែងសិល្បៈច្រើនពេក ឬស្នើសុំឲ្យទស្សនិកជនរង់ចាំនៅខាងក្រៅបរិវេណរោង ក្នុងករណីមកមុនម៉ោង។




## ១.៥- ការសំអាតអនាម័យ

- ត្រូវដាក់ទឹកអាល់កុលលាងដៃសម្រាប់ទស្សនិកជន នៅតាមកន្លែងសំខាន់ៗក្នុងបរិវេណរោងភាពយន្ត ឬរោងសម្តែងសិល្បៈ។
- ត្រូវលាងសម្អាតមេរោគឱ្យបានញឹកញាប់ នៅបញ្ជរនិងកន្លែងបិទបើកទ្វារ នៅពេលបញ្ចាំង ឬសម្តែងចប់ម្តងៗ។
- បន្ទប់ទឹកត្រូវលាងសំអាតយ៉ាងតិចពីរដងក្នុងមួយថ្ងៃ និងមិនត្រូវបោះសំរាមចោលក្នុងបរិវេណរោងភាពយន្ត ឬរោងសម្តែងសិល្បៈទេ។ សំរាមត្រូវដាក់ក្នុងធុងសំរាម ដោយត្រូវវេចខ្ចប់ឲ្យបានត្រឹមត្រូវ។ ចំពោះអ្នកសំអាតអនាម័យត្រូវមានវិធានការការពារ ដោយត្រូវពាក់ម៉ាស់ និងស្រោមដៃ ព្រមទាំងលាងសំអាតដៃជាប្រចាំដោយសាប៊ូ ឬទឹកអាល់កុលលាងដៃ។





## ១.៦- ការទិញអាហារសម្រន់

- ត្រូវសម្អាតកន្លែងលក់អាហារសម្រន់ និងរក្សាឱ្យមានអនាម័យជាប្រចាំ។ អ្នកលក់ត្រូវពាក់ម៉ាស និងពាក់ស្រោមដៃ។ រោងភាពយន្ត ឬរោងសម្តែងសិល្បៈ ត្រូវរកវិធានការបង់ប្រាក់ ដែលចៀសវាងការបង់ប្រាក់ដោយផ្ទាល់ តាមដែលអាចធ្វើបាន។







## ១.៧- នៅក្នុងរោងបញ្ចាំង ឬរោងសម្តែងសិល្បៈ

- អនុញ្ញាតឲ្យទស្សនិកជនចូលបានតែ ៥០% នៃចំនួនកៅអីសរុបតែប៉ុណ្ណោះ នៅក្នុងរោងបញ្ចាំង ឬរោងសម្តែងសិល្បៈនីមួយៗ។ ត្រូវរក្សាគំលាតរវាងទស្សនិកជនពីម្នាក់ទៅម្នាក់ទៀតយ៉ាងតិចចន្លោះ១.៥០ម។ ក្នុងករណីទស្សនិកជនចូលទស្សនាជាលក្ខណៈគ្រួសារ ដែលមានសមាជិកមិនលើសពី៥នាក់ អាចអនុញ្ញាតឲ្យអង្គុយក្បែរគ្នាបាន។
- ទ្វារនៃរោងបញ្ចាំង ឬរោងសម្តែងសិល្បៈ ត្រូវទុកឲ្យចំហមុននឹងចាប់បញ្ចាំងភាពយន្ត ឬសម្តែងសិល្បៈម្តងៗ។
- ត្រូវរក្សាសីតុណ្ហភាពក្នុងរោងបញ្ចាំង ឬរោងសម្តែងសិល្បៈជាមធ្យមចន្លោះពី ២៤អង្សារ ទៅ ៣០អង្សារ។






24C°-30C°

## ១.៨- កាត់បន្ថយចំនួនម៉ោងបញ្ចាំង ឬម៉ោងសម្តែង

- ត្រូវកាត់បន្ថយម៉ោងបញ្ចាំង ឬម៉ោងសម្តែង (Number of Session) ដើម្បីទុកចន្លោះពេល យ៉ាងតិច ៣០នាទី សម្រាប់ធ្វើការសម្អាតរោងបញ្ចាំង ឬរោងសម្តែង មុននឹងបន្តចាក់បញ្ចាំងភាពយន្ត ឬសម្តែងសិល្បៈជាថ្មី។





## ១.៩- ចាក់ផ្សាយសារអប់រំ

- ដើម្បីរួមចំណែកផ្សព្វផ្សាយ និងការពារការរីករាលដាលជំងឺកូវីដ១៩ រោងភាពយន្តត្រូវចាក់ផ្សាយសារអប់រំពីរបៀបការពារខ្លួនពីជំងឺកូវីដ១៩ រៀងរាល់ពេលមុននឹងចាក់បញ្ចាំងភាពយន្ត ដើម្បីក្រើនរំលឹកដល់ទស្សនិកជន។ ចំពោះរោងសម្តែងសិល្បៈ ត្រូវមានពិធីករថ្លែងសារអប់រំមុននឹងចាប់ផ្តើមការសម្តែង។






## ២- វិធានការត្រួតពិនិត្យ

- ករណីដែលរោងភាពយន្ត ឬរោងសម្តែងសិល្បៈណាមួយ មិនបានអនុវត្តតាមគោលការណ៍ស្តង់ដាប្រតិបត្តិនេះត្រង់ចំណុចទី១.១ ,ទី១.៣,ទី១.៤,ទី១.៥,ទី១.៦,ទី១.៨ និងទី១.៩ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនឹងស្នើឱ្យកែតម្រូវ និង/ឬធ្វើការព្រមានជាលាយលក្ខណ៍អក្សរ។ ករណីរោងភាពយន្ត ឬរោងសម្តែងសិល្បៈ មិនអនុវត្តតាមគោលការណ៍ស្តង់ដាប្រតិបត្តិនេះត្រង់ចំណុចទី១.២និងទី១.៧ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នឹងបញ្ឈប់ដំណើរការបញ្ចាំងភាពយន្ត ឬសម្តែងសិល្បៈជាបន្ទាន់ តាមរយៈលិខិតផ្លូវការ។
- ក្រុមការងារត្រួតពិនិត្យមួយត្រូវបានបង្កើតឡើងនៅតាមគោលដៅនៃរាជធានី-ខេត្ត ដែលមានសមាសភាពនៃនាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ ឬ នាយកដ្ឋានសិល្បៈទស្សនីយភាព, មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ មន្ទីរសុខាភិបាល និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីសហការចុះត្រួតពិនិត្យតាមដានដំណើរការរបស់រោងភាពយន្ត និងរោងសម្តែងសិល្បៈ ក្នុងការអនុវត្តគោលការណ៍ស្តង់ដាប្រតិបត្តិនេះឲ្យបានត្រឹមត្រូវ ដោយគ្មានការជូនដំណឹងជាមុន និងត្រូវរាយការណ៍ជាប្រចាំជូនក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងសុខាភិបាល។

ថ្ងៃពុធ ៦ រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**